**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ១៦ **អយក.**សណន

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តកម្មវិធីអប់រំកុមារតូច និងការពង្រឹងអភិបាលកិច្ច នៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាក្នុងក្របខ័ណ្ឌស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

ដើម្បីធានាសង្គតិភាពនៃការអនុវត្តកម្មវិធីអប់រំកុមារតូច និងពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈទាំងអស់ សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំកុមារតូចឱ្យកាន់តែរឹងមាំ មានបុរេសកម្ម និងទំនើបកម្ម ស្របតាមស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំដល់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដូចខាងក្រោម៖

**១. គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ**

- ត្រូវរៀបចំផែនការសកម្មភាព យន្តការ បែបបទ និងនីតិវិធីអនុវត្តតាមស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ដោយផ្អែកភាពជាម្ចាស់នៃស្វ័យដឹកនាំគ្រប់គ្រងរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនីមួយៗ។
- រៀបចំសំណើសុំការវាយតម្លៃតាមឋានានុក្រម ដើម្បីទទួលស្គាល់ជាសាលាមត្តេយ្យសិក្សាគំរូប្រចាំឆ្នាំ រួចបញ្ជូនមករដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅត្រឹមសប្តាហ៍ទី២ ខែតុលា រៀងរាល់ឆ្នាំ។

**២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

- ត្រូវរៀបចំផែនការសកម្មភាព យន្តការគាំទ្រ និងសម្របសម្រួលដល់ដំណើរការអនុវត្តកម្មវិធីអប់រំកុមារតូចនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈទាំងអស់ ឱ្យស្របតាមស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ
- បូកសរុប រៀបចំសំណើ និងបញ្ជូនរបាយការណ៍វាយតម្លៃមត្តេយ្យសិក្សាគំរូប្រចាំឆ្នាំទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត នៅត្រឹមសប្តាហ៍ទី៣ ខែតុលា រៀងរាល់ឆ្នាំ។

**៣. មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

- ត្រូវរៀបចំផែនការសកម្មភាព និងយន្តការគាំទ្រនានា ព្រមទាំងសហការជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ
- បូកសរុប និងរៀបចំសំណើ និងបញ្ជូនរបាយការណ៍វាយតម្លៃមត្តេយ្យសិក្សាគំរូប្រចាំឆ្នាំ មកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានអប់រំកុមារតូច) នៅត្រឹមសប្តាហ៍ទី៤ ខែតុលា រៀងរាល់ឆ្នាំ។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥[illegible]៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

❖ បញ្ជាក់៖ ខ្លឹមសារលម្អិតនៃការរៀបចំយន្តការ បែបបទ និងនីតិវិធីអនុវត្តតាមស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ត្រូវអនុវត្តតាមឯកសារស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា។

ទទួលបានសេចក្តីណែនាំនេះ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ រដ្ឋបាលក្រុង ខណ្ឌ ស្រុក មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  «ដើម្បីជូនជ្រាបជាព័ត៌មាន»
- អង្គភាពពាក់ព័ន្ធ
  «ដើម្បីសហការនិងអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ-នា.អកត